# I. ទីស្តីការគណៈរដ្ឋមន្ត្រី

*ភ្នំពេញចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៩៤*

## អនុក្រឹត្យ លេខ ៥២ អនក្រ
## ស្តីពីការបង្កើតគណៈកម្មការជាតិអចិន្ត្រៃយ៍
## ដើម្បី សំរបសំរួលកិច្ចការឯកជនភាវូបនីយកម្ម
## និង ការជំរុញវិស័យដំណាំកៅស៊ូ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យរបស់ ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណូមពរការងារចាំបាច់

### សំរេច

**មាត្រា ១:** បង្កើតគណៈកម្មការជាតិអចិន្ត្រៃយ៍ ដើម្បីសំរបសំរួលកិច្ចការឯកជនភាវូបនីយកម្មនិងការជំរុញវិស័យដំណាំកៅស៊ូដែលមានសមាសភាពដូចតទៅ ៖

១- ឯកឧត្តម ញឹម វណ្ណដា បេសកជនពិសេសរបស់នាយករដ្ឋមន្ត្រី ទី១ និង នាយករដ្ឋមន្ត្រីទី ២ សហប្រធាន

២-ឯកឧត្តម តាវ សេងហួ រដ្ឋលេខាធិការ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ សហប្រធាន

៣- ឯកឧត្តម ហេង វង្សប៊ុនឆាត អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ អនុប្រធាន

៤- ឯកឧត្តម ហ៊ុន ណេង អភិបាលខេត្តកំពង់ចាម អនុប្រធាន

៥- ឯកឧត្តម ប៊ុន អ៊ុយ អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក អចិន្ត្រៃយ៍

៦- ឯកឧត្តម ជា ប៉េងឈាង អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក

៧- ឯកឧត្តម អ៊ិត វិជិត អគ្គលេខាធិការគណៈកម្មាធិការជាតិវិនិយោគ សមាជិក

៨-ឯកឧត្តម តេង ឡាវ អគ្គនាយក អគ្គនាយកដ្ឋានចំការកៅស៊ូ សមាជិក

៩- ឯកឧត្តម អភិបាល ខេត្តរតនគីរី សមាជិក

១០- ឯកឧត្តម អភិបាល ខេត្តក្រចេះ សមាជិក

១១- លោក ហ្វីលីព ម៉ូណាំង ទីប្រឹក្សាអមអគ្គនាយកដ្ឋានចំការកៅស៊ូ សមាជិក

១២- លោក កុក សុខគឹម ទីប្រឹក្សា សមាជិក

មាត្រា ២ ៖ គណៈកម្មការជាតិនេះមានភារកិច្ចដូចខាងក្រោម ៖

- សិក្សា និង លើកគោលការណ៍ បែបបទ និង នីតិវិធីសំរាប់ការដាក់ឲ្យធ្វើឯកជនភាវូបនីយកម្ម និង ជំរុញការដាំដុះ និង ការធ្វើអាជីវកម្មដំណាំកៅស៊ូឲ្យស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

- ធ្វើការចរចា សំរបសំរួលការងារអោយបានឆាប់រហ័ស ជាមួយភាគីដៃគូ នៅក្នុង និង ក្រៅប្រទេសជាសាធារណៈ ឬជាឯកជនទាំងឡាយណាដែលផ្តល់ប្រសិទ្ធភាពខ្ពស់ ។

- រៀបចំឯកសារ ដែលមានការពាក់ព័ន្ធដល់ ការដាក់ឲ្យធ្វើឯកជនភាវូបនីយកម្មដំណាំកៅស៊ូ ដើម្បីសុំការអនុម័តពី រាជរដ្ឋាភិបាល ។

មាត្រា ៣ ៖ រចនាសម្ព័ន្ធ នៃ គណៈកម្មការជាតិមានដូចខាងក្រោម ៖

១- គណៈកម្មការនាំមុខក្រុមហ៊ុន នាំចេញ នាំចូល SAFIC ALCAN

២- គណៈកម្មការនាំមុខ ជប់-ក្រែក TERRES ROUGES

៣- គណៈកម្មការនាំមុខ ចំការអណ្តូង ប៊ឹងកេត មេមត់ ស្នួល SIPH

៤- គណៈកម្មការនាំមុខ តា ប៉ាំង CIRAD

៥- គណៈកម្មការនាំមុខ រតនគីរី

គណៈកម្មការជាតិ មានសិទ្ធិបង្កើតក្រុមការងាររបស់ខ្លួន ដែលមានសមាស-ភាព មកពីក្រសួងស្ថាប័ន ពាក់ព័ន្ធ ដើម្បីជាជំនួយការងារ ។

មាត្រា ៤ : សមាជិកគណៈកម្មការជាតិ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន និង មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ ។

មាត្រា ៥ :សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួងស្ថាប័នពាក់ព័ន្ធ និង ឯកឧត្តម អស់លោកដែលមានឈ្មោះ ក្នុងមាត្រា ១ ត្រូវទទួល អនុវត្តតាម អនុក្រឹត្យនេះចាប់ពី ថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និងត្រា | ហត្ថលេខា និង ត្រា |
| នរោត្តម រណឫទ្ធិ | ហ៊ុន សែន |

* * *

*ភ្នំពេញថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៩៤*

## អនុក្រឹត្យ លេខ ៥៣ អនក្រ

## ស្តីពីការផ្ទេរនិយ័តភាពថវិកា ឆ្នាំ ១៩៩៤ របស់ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ពីជំពូក ១០ និង ជំពូក ៣១ មកបំពេញឲ្យជំពូក ១១

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័នព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា